ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ

លេខ៖ ប៣៧៤/២០២៦ កបទ.សអ

សេចក្តីប្រកាសព័ត៌មាន

លទ្ធផលនៃកិច្ចប្រជុំពិគ្រោះយោបល់នយោបាយទ្វេភាគីលើកទី៤ រវាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងការបរទេស កំមិនវែល និងអភិវឌ្ឍន៍ នៃ រាជាណាចក្ររួមនៃព្រឺតថេននិងអៀរឡង់ខាងជើង

ឯកឧត្តម មាស គឹមហេង រដ្ឋលេខាធិការ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និង **លោក Mark Gooding** ប្រធាននាយកដ្ឋានអាស៊ីប៉ាស៊ីហ្វិក នៃក្រសួងការបរទេស កំមិនវែល និងអភិវឌ្ឍន៍ (FCDO) បានធ្វើសហប្រធាន ដឹកនាំកិច្ចប្រជុំពិគ្រោះយោបល់នយោបាយទ្វេភាគីកម្ពុជា-ព្រឺតថេនលើកទី៤ ដែលបានប្រព្រឹត្តទៅនៅទីក្រុងឡុងដ៍ ព្រឺតថេន នៅថ្ងៃទី ២២ និង ២៣ ខែតុលា ឆ្នាំ ២០២៦។

ជាលទ្ធផល ភាគីទាំងពីរ បានសម្តែងការពេញចិត្តចំពោះវឌ្ឍនភាព និងសន្ទុះរីកចម្រើនឥតឈប់ឈរនៃកិច្ចសហប្រតិបត្តិការទ្វេភាគីកន្លងមក តាមរយៈការផ្លាស់ប្តូរដំណើរទស្សនកិច្ចកម្រិតខ្ពស់ កំណើននៃការដោះដូរពាណិជ្ជកម្មទ្វេភាគី ការវិនិយោគ និងការបន្តអនុវត្តកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ជាដើម។ ក្នុងគោលបំណងជំរុញភាពជាដៃគូឲ្យបានកាន់តែទូលំទូលាយថែមទៀត ភាគីទាំងពីរបានចែករំលែកទស្សនៅវិញទៅមក អំពីការវិវត្តថ្មីៗ នៃសភាពការណ៍នយោបាយ និងសេដ្ឋកិច្ច ក្នុងប្រទេសទាំងពីរ ថែមទាំងបានពិភាក្សាអំពីឱកាសក្នុងការពង្រីកកិច្ចសហប្រតិបត្តិការលើវិស័យសក្តានុពលជាច្រើន មានដូចជា អប់រំ សុខាភិបាល វប្បធម៌ ទំនាក់ទំនងរវាងប្រជាជន ទេសចរណ៍ បរិស្ថាន សិទ្ធិមនុស្ស ការអភិវឌ្ឍជំនាញ បរិវត្តកម្មឌីជីថល ការបោសសម្អាតមីន និងការអភិវឌ្ឍប្រកបដោយចីរភាព។

ភាគីទាំងពីរបានគូសបញ្ជាក់អំពីអាទិភាពជាតិរៀងៗខ្លួន សំដៅស្វែងរកកាលានុវត្តភាពថ្មីៗទៀត ដែលអាចជំរុញពាណិជ្ជកម្ម និងការវិនិយោគបន្ថែមទៀត ពង្រឹងទំនាក់ទំនងរវាងធុរជន គាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាព នៅក្នុងបរិបទបន្ទាប់ពីកម្ពុជាចាកចេញពីឋានៈជាប្រទេសអភិវឌ្ឍន៍តិចតួចបំផុត នៅឆ្នាំ២០២៩។ ភាគីទាំងពីរក៏បានគូសបញ្ជាក់ផងដែរ អំពីសារៈសំខាន់នៃវេទិកាពាណិជ្ជកម្ម និងវិនិយោគរួម (JTIF) ដែលនឹងប្រព្រឹត្តទៅនៅឆ្នាំ២០២៧ និងគម្រោងពាណិជ្ជកម្មសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ (DCTS) ក្នុងការបន្តពង្រឹងភាពជាដៃគូសេដ្ឋកិច្ចរវាងកម្ពុជា និងព្រឺតថេន។

ភាគីទាំងពីរក៏បានស្វាគមន៍ដល់ការរីកចម្រើនថ្មីៗ ក្នុងកិច្ចសហប្រតិបត្តិការលើវិស័យការពារជាតិ និងសន្តិសុខ តាមរយៈការផ្លាស់ប្តូរទស្សនកិច្ច និងការកសាងសមត្ថភាពមន្ត្រីយោធា ហើយបានប្តេជ្ញាចិត្តរួមគ្នាបន្តប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មឆបោកអនឡាញ និងឧក្រិដ្ឋកម្មឆ្លងដែន ក៏ដូចជាការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវអនុស្សរណៈនៃការយោគយល់គ្នាពាក់ព័ន្ធនឹងការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា ដែលបានចុះហត្ថលេខាកាលពី ខែកញ្ញា ឆ្នាំ២០២៦។

ភាគីទាំងពីរ បានអះអាងឡើងវិញ អំពីការបន្តប្រើប្រាស់ច្បាប់អន្តរជាតិ គាំទ្រសន្តិភាព និងកិច្ចសន្ទនាប្រកបដោយស្ថាបនា ក្នុងការដោះស្រាយបញ្ហាប្រឈមក្នុងតំបន់ និងសកលលោក។ ក្នុងន័យនេះ **ឯកឧត្តមរដ្ឋលេខាធិការ** បានធ្វើបច្ចុប្បន្នភាពជូនភាគីព្រឹតថេន អំពីការខិតខំប្រឹងប្រែងការដោះស្រាយជម្លោះព្រំដែនកម្ពុជា-ថៃ រួមទាំងការដោះស្រាយបញ្ហាព្រំដែនសមុទ្រ តាមរយៈយន្តការគណៈកម្មការផ្សះផ្សាក្រោមអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ ព្រមទាំងបានគូសបញ្ជាក់អំពីការប្តេជ្ញាចិត្តរបស់កម្ពុជា ក្នុងការដោះស្រាយជម្លោះដោយសន្តិវិធី តាមរយៈយន្តការដែលមានស្រាប់ និងកិច្ចព្រមព្រៀងដែលបានឯកភាពគ្នារវាងភាគី និងអនុលោមតាមច្បាប់អន្តរជាតិ។

ក្នុងអំឡុងពេលស្នាក់នៅទីក្រុងឡុងដ៍ **ឯកឧត្តមរដ្ឋលេខាធិការ** បានចូលជួបសម្តែងការគួរសមជាមួយ Lord Hanson អនុរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង Lord Ed Vaizey ប្រធានក្រុមប្រឹក្សាធុរកិច្ចអាស៊ាន-ព្រឹតថេន នៅវិមានសភាជាន់ខ្ពស់ព្រឹតថេនផងដែរ។ **ឯកឧត្តមរដ្ឋលេខាធិការ** ក៏បានជួបពិភាក្សាការងារជាមួយ **លោកស្រី** Katy Reid ប្រធាននាយកដ្ឋានភូមិសាស្ត្រ និងភាសា នៃសាលាការទូតរបស់ក្រសួងការបរទេសព្រឹតថេន ដើម្បីផ្លាស់ប្តូរយោបល់អំពីលទ្ធភាពនៃការធ្វើកិច្ចសហប្រតិបត្តិការលើការកសាង និងអភិវឌ្ឍន៍សមត្ថភាពមន្ត្រីការទូត រវាងវិទ្យាស្ថានជាតិការទូត និងទំនាក់ទំនងអន្តរជាតិ និងសាលាការទូតក្រសួងការបរទេស ខំមិនវែល និងអភិវឌ្ឍន៍ព្រឹតថេន។

ឯកឧត្តមរដ្ឋលេខាធិការ រួមជាមួយគណៈប្រតិភូកម្ពុជា បានធ្វើទស្សនកិច្ចសិក្សា នៅសាកលវិទ្យាល័យ ឌឺ ម៉ុនហ្វត នៅទីក្រុងឡុងដ៍ និងបានជួបសំណេះសំណាលជាមួយនិស្សិតកម្ពុជា ដែលកំពុងសិក្សានៅទីក្រុងឡុងដ៍ ដោយមានការចូលរួមដោយ **ឯកឧត្តម** Dominic Williams ឯកអគ្គរាជទូតព្រឹតថេនប្រចាំកម្ពុជា។

កិច្ចប្រជុំពិគ្រោះយោបល់នយោបាយទ្វេភាគីខាងលើ បានបញ្ចប់ទៅប្រកបដោយជោគជ័យ ក្រោមបរិយាកាសកក់ក្តៅ និងស្និទ្ធស្នាល។ កិច្ចប្រជុំពិគ្រោះយោបល់នយោបាយទ្វេភាគីលើកទី៥ នឹងប្រព្រឹត្តទៅនៅទីក្រុងភ្នំពេញ នៅឆ្នាំ២០២៧។

ថ្ងៃ សុក្រ ៤កើត ខែអស្សុជ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
ភ្នំពេញ ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២៦